ព្រះរាជាណាចក្រកម្ពុជា

ជាតិ សាសនា ព្រះមហាក្សត្រ

ក្រសួងសង្គមកិច្ច ការងារ បណ្តុះបណ្តាលវិជ្ជាជីវៈ

និងយុវនីតិសម្បទា

លេខ: ០៥២ សកបយ.

រាជធានីភ្នំពេញ , ថ្ងៃទី ១០ ខែ កុម្ភៈ ឆ្នាំ២០០០

# ប្រកាស

## ស្តីពី

## ការរៀបចំបង្គន់អនាម័យ

**រដ្ឋមន្ត្រីក្រសួងសង្គមកិច្ច ការងារ បណ្តុះបណ្តាលវិជ្ជាជីវៈ និងយុវនីតិសម្បទា**

-បានឃើញរដ្ឋធម្មនុញ្ញ នៃព្រះរាជាណាចក្រកម្ពុជា

-បានឃើញព្រះរាជក្រឹត្យលេខ នស/រកត/១១៩៨/៧២ ចុះថ្ងៃទី៣០ ខែវិច្ឆិកា ឆ្នាំ១៩៩៨ ស្តីពីការតែងតាំងរាជរដ្ឋាភិបាល នៃព្រះរាជាណាចក្រកម្ពុជា

-បានឃើញព្រះរាជក្រមលេខ០២/នស/៩៤ ចុះថ្ងៃទី២០ ខែកក្កដា ឆ្នាំ១៩៩៤ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីការរៀបចំ និងការប្រព្រឹត្តិទៅ នៃគណៈរដ្ឋមន្ត្រី

-បានឃើញព្រះរាជក្រមលេខ ជស/រកម/០៣៩៧/០១ ចុះថ្ងៃទី១៣ ខែមីនា ឆ្នាំ១៩៩៧ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីការងារ

-បានឃើញព្រះរាជក្រមលេខ នស/រកម/០៦៩៩/០៦ ចុះថ្ងៃទី១៧ ខែមិថុនា ឆ្នាំ១៩៩៩ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីការបង្កើតក្រសួងសង្គមកិច្ច ការងារ បណ្តុះបណ្តាលវិជ្ជាជីវៈ និងយុវនីតិសម្បទា

-បានឃើញអនុក្រឹត្យលេខ ៨៧ អនក្រ/បក ចុះថ្ងៃទី០៤ ខែតុលា ឆ្នាំ១៩៩៩ ស្តីពីការរៀបចំ និងការប្រព្រឹត្តិទៅរបស់ក្រសួងសង្គមកិច្ច ការងារ បណ្តុះបណ្តាលវិជ្ជាជីវៈ និងយុវនីតិសម្បទា។

## <u>សំរេច</u>

**ប្រការ១.-** និយោជកនៃសហគ្រាស គ្រឹះស្ថាន ដូចមានចែងក្នុងមាត្រា១ នៃច្បាប់ស្តីពីការងារ ត្រូវរៀបចំឱ្យមាននៅក្នុងបរិវេណសហគ្រាស គ្រឹះស្ថានរបស់ខ្លួននូវបង្គន់សំរាប់ឱ្យកម្មករនិយោជិត បានប្រើប្រាស់ដោយសមរម្យ និងមានអនាម័យល្អ ។

**ប្រការ២.-** ចំនួនបង្គន់ត្រូវរៀបចំឱ្យមានសំរាប់ភេទប្រុស និងស្រី ដាច់ផ្សេងគ្នាទៅតាមចំនួនកម្មករនិយោជិត ដូចតារាងខាងក្រោមនេះ :-

| ចំនួនកម្មករនិយោជិត (ប្រុស ឬ ស្រី) | ចំនួនបង្គន់ |
|---|---|
| ១ នាក់ - ១៥ នាក់ | ១ |
| ១៦ នាក់ - ៣៥ នាក់ | ២ |
| ៣៦ នាក់ - ៥៥ នាក់ | ៣ |
| ៥៦ នាក់ - ៨០ នាក់ | ៤ |
| ៨១ នាក់ - ១១០ នាក់ | ៥ |
| ១១១ នាក់ - ១៥០ នាក់ | ៦ |
| ១៥១ នាក់ - ១០០០ នាក់ | ថែម ១ សំរាប់ ៥០ នាក់ |
| លើសពី ១.០០០ នាក់ | ថែម ១ សំរាប់៧០ នាក់ |

**ប្រការ៣.-** ការសាងសង់ត្រូវធ្វើអោយបានដូចខាងក្រោមៈ-

- កំរាលក្រោម និងជញ្ជាំងមិនជ្រាបទឹក
- ទ្វារជិត និងមានគន្លឹះសំរាប់ខ្ទាស់ពីក្នុង
- ជញ្ជាំងត្រូវលាបពិណភ្លឺ
- មានពន្លឺល្អ
- មានតាក តភ្ជាប់ពីកន្លែងធ្វើការទៅបង្គន់ ដើម្បីការពារទឹកភ្លៀង ។ ក្នុងករណីមិនអាចធ្វើតាមបាន និយោជកត្រូវផ្តល់មធ្យោបាយផ្សេងទៀត ដើម្បីការពារទឹកភ្លៀង ។

**ប្រការ៤.-** ត្រូវរៀបចំយ៉ាងណាឱ្យទឹកដែលបង្ហូរចេញពីបង្គន់ ស្របតាមក្បួនអនាម័យ ។

**ប្រការ៥.-** ចំពោះសហគ្រាស គ្រឹះស្ថាន ដែលមានប្រើកម្មករនិយោជិតជាស្ត្រីភេទចាប់ពីមួយរយនាក់ឡើងទៅត្រូវធ្វើបង្គន់ខ្ពស់ ដែលអាចអង្គុយផ្ទាល់ពីលើបានបន្ថែមមួយសំរាប់ស្ត្រីហាសិបនាក់ ។

**ប្រការ៦.-** ទឹកសំរាប់ប្រើប្រាស់នៅតាមបង្គន់ត្រូវឱ្យបានគ្រប់គ្រាន់ មានសភាពស្អាត និងថ្លា ។ សាប៊ូក៏ត្រូវមានគ្រប់គ្រាន់នៅតាមបង្គន់នីមួយៗ ។ បង្គន់ទាំងអស់ត្រូវបានទទួលការសំអាត ថែទាំ ដុសលាង យ៉ាងហោចបានម្តងក្នុងមួយថ្ងៃ ។

**ប្រការ៧.-** អ្នកប្រព្រឹត្តល្មើសនឹងបទប្បញ្ញត្តិទាំងឡាយនៃប្រកាសនេះ ត្រូវពិន័យ ឬទទួលទោស ដូចមានចែងក្នុងជំពូកទី១៦ នៃច្បាប់ស្តីពីការងារ ។

**ប្រការ៨.-** ប្រកាសនេះមានប្រសិទ្ធិភាពអនុវត្ត ចាប់ពីថ្ងៃចុះហត្ថលេខាតទៅ ។

**រដ្ឋមន្ត្រី**

**ក្រសួងសង្គមកិច្ច ការងារ បណ្តុះបណ្តាលវិជ្ជាជីវៈ និងយុវនីតិសម្បទា**

**ហត្ថលេខា និង ត្រា**

**អ៊ិត សំហេង**